**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ហៅកាត់ថា អ.ស.អ អនុលោមតាមមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ២.-**

តួនាទី និងភារកិច្ចរបស់ អ.ស.អ មានជាអាទិ៍ដូចតទៅ :

- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- លើកសំណើជូនក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពិនិត្យ និងសំរេច នូវទស្សនទាន កំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ យុទ្ធសាស្ត្រ គំរោងផែនការ ព្រមទាំងកម្មវិធីការងារសំរាប់ ធ្វើអោយសំរេចគោលដៅទាំងឡាយនៃទស្សនទាននោះ
- តាមដានអនុវត្តកម្មវិធីយុទ្ធសាស្ត្រ និង ផែនការសកម្មភាពកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ហើយរាយការណ៍ពីលទ្ធផលទទួលបានជូនក្រុម ប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- រៀបចំការប្រជុំនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌អោយបានជាប្រចាំ
- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នយុត្តិធម៌ និងស្ថាប័ននានា ដែលពាក់ព័ន្ធ នឹងកិច្ចការកែ ទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ធ្វើការសំរបសំរួលជាមួយអង្គការជាតិ និងអន្តរជាតិ និងតំណាងប្រទេសផ្តល់ជំនួយ ដើម្បីជំរុញ ប្រតិបត្តិការដៃគូអោយបានរឹងមាំ
- ផ្តល់ជូន ក្រសួង ស្ថាប័នរដ្ឋ តាមសមត្ថភាព និងលទ្ធភាពរបស់ខ្លួន នូវបង្អែកបច្ចេកទេសចាំបាច់
- លើកសំណើតែងតាំង តាមករណីចាំបាច់ នូវអ្នកជំនាញការជាតិ អន្តរជាតិ និងឥស្សរជន ឬមន្ត្រី ជាន់ខ្ពស់ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ចជាទី ប្រឹក្សា ឬជំនួយការ ដើម្បីសិក្សាវិភាគលើគំរោងយុទ្ធសាស្ត្រ និង ផែនការសកម្មភាពនានា លើ វិស័យកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជន ដែលមានគុណសម្បត្តិមកចូលរួមប្រជុំពិគ្រោះ យោបល់
- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- អនុវត្តរាល់ភារកិច្ច ដែលសហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ប្រគល់ឱ្យ ។

**មាត្រា ៣.-**

ភារកិច្ច និងបេសកកម្មពាក់ព័ន្ធកំណែទំរង់ច្បាប់មានជាអាទិ៍ដូចតទៅ :

- ពង្រឹងសមត្ថភាព កសាងច្បាប់ នៅតាមស្ថាប័នរដ្ឋ
- រៀបចំនីតិវិធីនៃការព្រាងច្បាប់អោយមានប្រសិទ្ធិភាព
- តាមដាន និងជំរុញការងារកសាងច្បាប់ អោយស្របទៅតាមនីតិវិធីជាធរមាន



ហ

- សំរបសំរួលការផ្តួចផ្តើមកសាងច្បាប់រវាង ក្រសួង ស្ថាប័ន អង្គភាព និងអង្គការអន្តរជាតិដទៃទៀត
- រៀបចំសន្ទានុក្រម និងវចនានុក្រម វាក្យស័ព្ទពាក្យពេចន៍ និងប្រជុំពាក្យផ្នែកច្បាប់ ដើម្បីសំរួលដល់ការងារព្រាងច្បាប់
- ជំរុញអោយមានការផ្សព្វផ្សាយច្បាប់ និងបទបញ្ញាទាំងឡាយអោយកាន់តែប្រសើរឡើង ព្រមទាំងរៀបចំសិក្ខាសាលា ដើម្បីពន្យល់ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ
- រៀបចំកម្មវិធី និងបង្កើតយន្តការការពារសិទ្ធិជាមូលដ្ឋាន របស់ប្រជាពលរដ្ឋអោយបានកាន់តែប្រសើរឡើង ។

**មាត្រា ៤.-**

ភារកិច្ច និងបេសកកម្មទាក់ទងនឹងកំណែទំរង់ប្រព័ន្ធយុត្តិធម៌មានជាអាទិ៍ដូចតទៅ :

- រៀបចំកម្មវិធីពង្រឹងសេវាយុត្តិធម៌ ដោយជំរុញអោយមានឯករាជ្យភាព ការជឿទុកចិត្ត មានតម្លាភាព និងការទទួលខុសត្រូវខ្ពស់របស់ចៅក្រម
- រៀបចំកម្មវិធីបង្កើនគុណភាពនៃសេវាប្រព័ន្ធយុត្តិធម៌ តាមរយៈការផ្តល់ជំនួយសេវាផ្នែកច្បាប់អោយមានគុណភាពខ្ពស់ ការបង្កើនចំនួនមេធាវី ការផ្តល់ការអប់រំ និងបណ្តុះបណ្តាល អោយមានប្រសិទ្ធិភាពខ្ពស់
- រៀបចំកម្មវិធី ដើម្បីធ្វើអោយប្រសើរឡើងនូវប្រព័ន្ធសំរាប់អនុវត្តសេចក្តីសំរេចរបស់តុលាការ
- ជំរុញអោយមានមូលដ្ឋានទិន្នន័យនៃសេចក្តីសំរេចរបស់តុលាការពីមុនៗមក
- រៀបចំនីតិវិធីនិងយន្តការដោះស្រាយជម្លោះ ដើម្បីជំនួសការកាត់សេចក្តីសាមញ្ញ ដោយបង្កើតអោយមានមជ្ឈត្តកម្មពាណិជ្ជកម្ម និងយន្តការសំរាប់ដោះស្រាយវិវាទតូចតាចតាមរយៈការសំរុះសំរួល ។

**មាត្រា ៥.-**

អង្គភាពសំរបសំរួលអចិន្ត្រៃយ៍នេះមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ស៊ុំ ម៉ាន់ិត** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកក្រុមប្រឹក្សាកំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុង ចន្ទសម្ផស្សនារា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

| | | |
|---|---|---|
| ៤- ឯកឧត្តម **សំ សុខផល** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៥- ឯកឧត្តម **ទី នាឃី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ឡេីល មួន** | សមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម | សមាជិក |
| ៧- ឯកឧត្តម **ក្រាញ់ ជ័យលាភីតូនី** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- ឯកឧត្តម **ម៉ៅ ថូរ៉ា** | អគ្គនាយករងបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- បណ្ឌិត **គិញ ចំនួនទិមុល** | តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |

**មាត្រា ៦.-**

អ.ស.អ ត្រូវធ្វើការប្រជុំ តាមការអញ្ជើញរបស់ប្រធានអង្គភាព យ៉ាងតិចឱ្យបានម្តងក្នុងមួយខែ ។

**មាត្រា ៧.-**

អ.ស.អ ត្រូវមានអង្គភាពគ្រប់គ្រងគំរោងមួយ ដើម្បីជាជំនួយដល់ប្រធាន អ.ស.អ ក្នុងកិច្ចការរដ្ឋបាលទូទៅ និងកិច្ចការហិរញ្ញវត្ថុរបស់គំរោងនៃការកែទំរង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ។ អង្គភាពនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញភារកិច្ចនិងបេសកកម្មរបស់ខ្លួន ។

**មាត្រា ៨.-**

អ.ស.អ អាចបង្កើត និងអាចពង្រីករចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួន ទៅតាមទំហំការងារជាក់ស្តែង ដើម្បីអនុវត្តយុទ្ធសាស្ត្រ គំរោងអោយមានប្រសិទ្ធិភាព ។

**មាត្រា ៩.-**

អ.ស.អ មានសិទ្ធិទទួលប្រាក់អំណោយ និងកិច្ចឧបត្ថម្ភផ្សេងៗផ្ទាល់ពីប្រទេស ស្ថាប័ន ឬអង្គការអន្តរជាតិនានា ។

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ស្ថាប័នដែលពាក់ព័ន្ធ និង ប្រធានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៥ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋ**

**ហ៊ុន សែន**

***បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី***

***"ដើម្បីសុំហត្ថលេខា"***

***សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌***

**ឱក មន្ទី** **សុខ អាន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ